ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

# របាយការណ៍ ៩ ខែ ដើមឆ្នាំ

# ស្តីពី

# ការអនុវត្តផែនការសកម្មភាព និងថវិកា

# ឆ្នាំ ២០១៧  របស់ គ.ជ.អ.ប

រៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប

ខែតុលា ឆ្នាំ២០១៧

**សេចក្តីសង្ខេប** ២
I.**សេចក្តីផ្តើម** ៤
II. **វឌ្ឍនភាព** ៥
**ក. សមិទ្ធផលទី១÷ ការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់** ៥
**ខ. សមិទ្ធផលទី២÷ គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ** ៧
**គ. សមិទ្ធផលទី៣÷ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស** ៩
**ឃ.សមិទ្ធផលទី៤÷ ការផ្តល់សេវា និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** ១១
**ង. សមិទ្ធផលទី៥÷ វិមជ្ឈការហិរញ្ញវត្ថុ** ១២
III. **បញ្ហាប្រឈម** ១៥
IV. **ស្ថានភាពថវិកា** ១៧
V. **ទិសដៅសម្រាប់ត្រីមាសទី៤ ឆ្នាំ២០១៧** ១៨

# សេចក្តីសង្ខេប

ផែនការសកម្មភាព និងថវិកា (ផ.ស.ថ) ២០១៧ គឺជាផែនការប្រចាំឆ្នាំចុងក្រោយនៃផ.អ.៣ទី២ (២០១៥-២០១៧) នៃកម្មវិធីជាតិរយៈពេល១០ឆ្នាំ ស្តីពីការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ផ.ស.ថ ឆ្នាំ២០១៧ ត្រូវបានអនុម័តដោយ គ.ជ.អ.ប កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ បន្ទាប់ពីបានរៀបចំ និងមានការជជែកពិភាក្សាជាបន្តបន្ទាប់ជាមួយអ្នកពាក់ព័ន្ធនានា។ ផ្អែកលើ ផ.ស.ថ នេះ គ.ជ.អ.ប បានសម្របសម្រួលជាមួយក្រសួង ស្ថាប័នអនុវត្តចំនួន៤៦ ដែលក្នុងនោះរួមមាន ក្រសួង ស្ថាប័ននានាចំនួន២១ និងរាជធានី ខេត្តចំនួន២៥ ក្នុងការរៀបចំនូវសេចក្តីសម្រេចរួមជាមួយនឹងក្រសួង ស្ថាប័នអនុវត្តនីមួយៗ និងបានចុះហត្ថលេខាលើសេចក្តីសម្រេចរួមទាំងនោះបានរួចរាល់ទាំងស្រុងនៅខែមីនា ឆ្នាំ២០១៧។ ទោះបីសេចក្តីសម្រេចរួមជាមួយក្រសួង ស្ថាប័នអនុវត្ត ត្រូវបានរៀបចំបញ្ចប់រហូតដល់ខែមីនាក៏ដោយ ក៏លេខាធិការដ្ឋានគ.ជ.អ.ប.បានផ្ទេរថវិកាជាបឋមមួយចំនួនដល់ក្រសួង ស្ថាប័នអនុវត្តនានាតាំងពីដើមខែមករា ដើម្បីគាំទ្រដល់ការចំណាយលើកិច្ចការរដ្ឋបាល និងសកម្មភាពសំខាន់ៗមួយចំនួន។ ថវិកាទាំងនេះបានមកពីថវិកាដែលបានផ្ទេរពីឆ្នាំ២០១៦ ដោយឡែកថវិកាដែលបានសន្យាផ្តល់ពីដៃគូអភិវឌ្ឍន៍ (Sida និង SDC) សម្រាប់ឆ្នាំ២០១៧ ត្រូវបានផ្ទេរមកឱ្យលេខាធិការដ្ឋាន គ.ជ.អ.ប នៅខែឧសភា ឆ្នាំ២០១៧ និងពីសហភាពអឺរ៉ុបតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅខែកញ្ញា ឆ្នាំ២០១៧កន្លងមកនេះ។

ផ.ស.ថ ឆ្នាំ២០១៧ រួមមានសមិទ្ធផលរំពឹងទុកចំនួន៥ ពោលគឺ ១).ការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់ ២).ការលើកកម្ពស់គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ៣).ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ៤).ការផ្តល់សេវា និងមុខងារ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និង ៥).វិមជ្ឈការហិរញ្ញវត្ថុ។ ដើម្បីសម្រេចបានសមិទ្ធផលរំពឹងទុកទាំង៥ខាងលើនេះ ផ.ស.ថ ឆ្នាំ២០១៧ បានគ្រោងនូវលទ្ធផលរំពឹងទុកចំនួន៣៧ ដែលក្នុងនោះរួមមានលទ្ធផលរំពឹងទុកជាអាទិភាពចំនួន២២ និងលទ្ធផលរំពឹងទុកដែលត្រូវអនុវត្តជាប្រចាំ និងមានលក្ខណៈជាការគាំទ្រចំនួន១៥។ លទ្ធផល រំពឹងទុកទាំង៣៧នេះត្រូវបានគ្រោងអនុវត្ត តាមរយៈការរៀបចំជាសកម្មភាពចម្បងៗដែលត្រូវអនុវត្តទៅតាមត្រីមាសនីមួយៗ និងបានគ្រោងថវិកាចំណាយ ព្រមទាំងមានការកំណត់នូវស្ថាប័នដែលទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនីមួយៗ។ ផ.ស.ថ ឆ្នាំ២០១៧ ក៏បានគ្រោងថវិកាសរុបចំនួនប្រមាណ៤៣៨លានដុល្លារ ដែលក្នុងនោះរួមមាន ថវិកាដែលត្រូវផ្ទេរពីថវិកាជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិចំនួនប្រមាណ៣៩៧លានដុល្លារ ថវិកាដែលគាំទ្រគម្រោងដាច់ដោយឡែកនានារបស់ដៃគូអភិវឌ្ឍន៍ចំនួនប្រមាណ២៧លានដុល្លារ និងថវិកាកញ្ចប់រួមសម្រាប់គាំទ្រដល់កិច្ចប្រតិបត្តិការ ជំនួយបច្ចេកទេស និងសកម្មភាពចំនួនប្រមាណ១១,៦លានដុល្លារ។

របាយការណ៍នេះរៀបរាប់អំពីវឌ្ឍនភាព និងបញ្ហាប្រឈមពាក់ព័ន្ធទៅនឹងការអនុវត្តសកម្មភាពចម្បងៗដែលបានកំណត់នៅក្នុងលទ្ធផលរំពឹងទុកជាអាទិភាពចំនួន២២ ដើម្បីឈានទៅសម្រេចនូវសមិទ្ធផលរំពឹងទុកទាំង៥ដូចបានរៀបរាប់ខាងលើ ព្រមទាំងស្ថានភាពនៃការគ្រប់គ្រងថវិកា របស់ គ.ជ.អ.ប រហូតដល់ចុងខែកញ្ញា ឆ្នាំ២០១៧។

ជារួម រហូតមកដល់ដំណាច់ត្រីមាសទី៣ សកម្មភាពចម្បងៗដែលបានគ្រោងអនុវត្តក្នុងចន្លោះពេលពីត្រីមាសទី១ដល់ត្រីមាសទី៣នៃលទ្ធផលរំពឹងទុកជាអាទិភាពចំនួន១៩ បានអនុវត្តសម្រេចតាមក្របខ័ណ្ឌពេលវេលា និងលទ្ធផលរំពឹងទុកជាអាទិភាពចំនួន៣ ពុំទាន់បានសម្រេចតាមក្របខ័ណ្ឌពេលវេលាដែលបានគ្រោងទុក។

ទន្ទឹមនឹងលទ្ធផលសម្រេចបានខាងលើនេះ រួមមានបញ្ហាប្រឈមមួយចំនួនដែលបង្កឱ្យមានភាពយឺតយ៉ាវ និងជាឧបសគ្គនៃការអនុវត្ត ផ.ស.ថ ឆ្នាំ២០១៧ ដែលក្នុងនោះរួមមាន ១).ការទម្លាក់ថវិកាពីដៃគូអភិវឌ្ឍន៍នៅតែមានភាព

យឺតយ៉ាវ ២).កិច្ចដំណើរការផ្ទេរមុខងារនៅមានភាពយឺតយ៉ាវ ៣).ប្រព័ន្ធអធិការកិច្ចទៅលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅពុំទាន់មានប្រសិទ្ធភាព ៤).ការប្រាស្រ័យទាក់ទង និងផ្សព្វផ្សាយព័ត៌មាននៅមានកម្រិត ៥).ការអនុវត្តមូលនិធិក្រុង ស្រុកនៅពុំទាន់ឆ្លើយតបនឹងតម្រូវការនៃការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន និង ៦).ការចូលរួមរបស់ក្រសួង ស្ថាប័ននៅក្នុងកិច្ចដំណើរការកំណែទម្រង់នៅមានកម្រិតនៅឡើយ។

យ៉ាងណាមិញ បញ្ហាដែលបានចោទឡើងខាងលើនេះ រួមមានបញ្ហាប្រឈមមួយចំនួនដែលត្រូវបន្តដោះស្រាយចំពោះមុខក្នុងត្រីមាសទី៤ នៃឆ្នាំ២០១៧ ហើយក៏មានបញ្ហាប្រឈមមួយចំនួនដែលចាំបាច់ត្រូវបន្តដោះស្រាយក្នុងរយៈពេលយូរអង្វែង ជាពិសេសនៅក្នុងដំណាក់កាលនៃការអនុវត្តផែនការអនុវត្ត៣ឆ្នាំដំណាក់កាលចុងក្រោយ (២០១៨-២០២០) នៃកម្មវិធីជាតិ។

រហូតមកទល់នឹងខែកញ្ញា ឆ្នាំ២០១៧ ក្នុងក្របខ័ណ្ឌថវិកាកញ្ចប់រួមរបស់ ផ.ស.ថ ឆ្នាំ២០១៧ របស់ គ.ជ.អ.ប ដែលបានគ្រោងចំនួន១១,៦លានដុល្លារ លេខាធិការដ្ឋាន គ.ជ.អ.ប បានទទួលថវិកាពីដៃគូអភិវឌ្ឍន៍ចំនួនប្រមាណ ៨,២ លានដុល្លារ ដែលក្នុងនោះរួមមានថវិកាដែលបានផ្ទេរពីឆ្នាំ២០១៦ មានចំនួនប្រមាណ១,៥ លានដុល្លារ ថវិកាដែលបានផ្ទេរពី Sida ចំនួនប្រមាណ២,៧លានដុល្លារ និងពី SDC ចំនួនប្រមាណ១លានដុល្លារនៅខែឧសភា ព្រមទាំងថវិការបស់សហភាពអឺរ៉ុបដែលបានផ្ទេរតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន៣លានដុល្លារនាខែកញ្ញាថ្មីៗកន្លងមកនេះ។ យោងតាម ផ.ស.ថ ឆ្នាំ២០១៧ និងក្នុងក្របខ័ណ្ឌថវិកាកញ្ចប់រួមដែលលេខាធិការដ្ឋានគ.ជ.អ.ប ទទួលបានជាបន្តបន្ទាប់ដូចបានរៀបរាប់ខាងលើ ការចំណាយលើការអនុវត្តកម្មវិធីគិតមកដល់ចុងខែកញ្ញា មានចំនួនសរុបជិត៦លានដុល្លារ ដែលស្មើនឹងចំនួន៥០% នៃផែនការថវិកាកញ្ចប់រួមរបស់ ផ.ស.ថ ឆ្នាំ២០១៧។ ការចំណាយដែលមានចំនួនភាគរយទាបធៀបនឹងចិរវេលានៃផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ គឺបណ្តាលមកពីភាពយឺតយ៉ាវនៃការរៀបចំ សេចក្តីសម្រេចរួមរវាងក្រសួង ស្ថាប័នអនុវត្តទាំង៤៦ជាមួយនឹង គ.ជ.អ.ប ដែលបានប្រើប្រាស់ពេលវេលាប្រមាណពី ៣ទៅ៤ ខែនៅដើមឆ្នាំ ព្រមទាំងបណ្តាលមកពីភាពយឺតយ៉ាវនៃការផ្ទេរថវិកាពីដៃគូអភិវឌ្ឍន៍មួយចំនួនដូចបានរៀបរាប់ខាងលើ។ យ៉ាងណាមិញ រហូតទៅដល់ចុងឆ្នាំ២០១៧នេះ លេខាធិការដ្ឋាន គ.ជ.អ.ប បានព្យាករណ៍ពីការចំណាយដែលអាចមានចំនួនប្រមាណ៨០% នៃផែនការថវិកាកញ្ចប់រួមរបស់ ផ.ស.ថ ឆ្នាំ២០១៧។

# I.សេចក្តីផ្តើម

ផែនការអនុវត្តបីឆ្នាំ ដំណាក់កាលទី២ (ផ.អ.៣ទី២) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានអនុម័តដោយ គ.ជ.អ.ប នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤។ ផ.អ.៣ទី២ ត្រូវបានរៀបចំឡើងដោយផ្អែកលើភាពជោគជ័យ បញ្ហាប្រឈម និងបទពិសោធន៍នៃការអនុវត្ត ផ.អ.៣ទី១ និងបានកំណត់នូវបញ្ហាជាគន្លឹះនានា ដើម្បីអនុវត្តនៅក្នុងរយៈពេល៣ឆ្នាំ (២០១៥-២០១៧) បន្តទៀត។ ផ.អ.៣ទី២ ផ្តោតការយកចិត្តទុកដាក់ខ្ពស់ទៅលើការបន្តពង្រឹងរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានដាក់ឱ្យអនុវត្តនៅក្នុងដំណាក់កាលនៃ ផ.អ.៣ទី១ សំដៅលើកកម្ពស់តួនាទី ការទទួលខុសត្រូវ និងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។ ផ.អ.៣ទី២ នៅតែបន្តផ្តោតទៅលើការសម្រេចឱ្យបាននូវសមិទ្ធផលរំពឹងទុកទាំង៥ ដែលបានកំណត់នៅក្នុងកម្មវិធីជាតិ ពោលគឺ៖ ១).ការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់ ២).ការលើកកម្ពស់គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ៣).ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ៤).ការផ្តល់សេវា និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និង ៥).វិមជ្ឈការហិរញ្ញវត្ថុ។

ដើម្បីឈានដល់ការសម្រេចបាននូវសមិទ្ធផលរំពឹងទុកទាំង៥ របស់ ផ.អ.៣ទី២ គ.ជ.អ.ប បានរៀបចំ ផ.ស.ថ ប្រចាំឆ្នាំនីមួយៗដោយបានកំណត់ពីលទ្ធផលរំពឹងទុក យុទ្ធសាស្ត្រ សកម្មភាពចម្បងៗ និងចំណុចដៅដែលត្រូវអនុវត្តប្រចាំឆ្នាំនីមួយៗ។ ក្នុងក្របខ័ណ្ឌនៃ ផ.ស.ថ ឆ្នាំ២០១៧ របស់ គ.ជ.អ.ប បានកំណត់នូវលទ្ធផលរំពឹងទុកចំនួន៣៧ ដែលក្នុងនោះរួមមានលទ្ធផលរំពឹងទុកជាអាទិភាពចំនួន២២ និងលទ្ធផលរំពឹងទុកដែលត្រូវអនុវត្តជាប្រចាំ និងមានលក្ខណៈជាការគាំទ្រចំនួន១៥។

របាយការណ៍នេះ បង្ហាញពីវឌ្ឍនភាព បញ្ហាប្រឈម ស្ថានភាពថវិកា និងទិសដៅពាក់ព័ន្ធនឹងលទ្ធផលរំពឹងទុកជាអាទិភាពចំនួន២២ នៃ ផ.ស.ថ ឆ្នាំ២០១៧ របស់ គ.ជ.អ.ប គិតចាប់ពីខែមករា ដល់ខែកញ្ញា ឆ្នាំ២០១៧។

## II. វឌ្ឍនភាព

### ក. សមិទ្ធផលទី១៖ ការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់

សមិទ្ធផលនេះ រួមមានលទ្ធផលរំពឹងទុកជាអាទិភាពចំនួន៤ ដែលក្នុងនោះលទ្ធផលរំពឹងទុកជាអាទិភាពចំនួន៣ បានអនុវត្តសម្រេចតាមផែនការដែលបានគ្រោងទុក និងលទ្ធផលរំពឹងទុកជាអាទិភាពចំនួន១ពុំបានសម្រេចតាមផែនការដែលបានគ្រោងទុក។ វឌ្ឍនភាពនៃលទ្ធផលរំពឹងទុកនីមួយៗមានរៀបរាប់ដូចខាងក្រោម៖

**លទ្ធផលរំពឹងទុកជាអាទិភាពទី១៖ ការរៀបចំកិច្ចប្រជុំរបស់ គ.ជ.អ.ប ដើម្បីដឹកនាំនិងសម្របសម្រួលការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

លទ្ធផលរំពឹងទុកនេះបានអនុវត្តសម្រេចតាមផែនការ ដែលរួមមានលទ្ធផលនៃការអនុវត្តដូចខាងក្រោម៖

- គ.ជ.អ.ប បានរៀបចំកិច្ចប្រជុំលើកទី១៣ កាលពីថ្ងៃទី៤ ខែមករា ឆ្នាំ២០១៧ ដោយបានពិភាក្សា និងអនុម័តលើឯកសារមួយចំនួន ពោលគឺ ១).ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧ ២).សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយ សម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ៣).សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋ ៤).សេចក្តីព្រាងសេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ៥).សេចក្តីព្រាងសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ៦).សំណើបញ្ជីមុខងារចំនួន២៨ ដែលគ្រោងផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និង ៧).ឯកសារបំពេញបន្ថែមទៅលើកម្មវិធីជាតិ។
- គ.ជ.អ.ប បានរៀបចំកិច្ចប្រជុំលើកទី១៤ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧នេះ ដើម្បី ១).ពិភាក្សា និងអនុម័តរបាយការណ៍ស្តីពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តរយៈពេល៩ខែដើមឆ្នាំនៃផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧ របស់ គ.ជ.អ.ប ២).ពិភាក្សា និងអនុម័តលើសេចក្តីព្រាងឯកសារផែនការអនុវត្ត៣ឆ្នាំ (២០១៨-២០២០) ដំណាក់កាលទី៣ (ផ.អ.៣ទី៣) នៃកម្មវិធីជាតិ ៣).ពិភាក្សា និងអនុម័តលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការធ្វើប្រតិភូកម្មអំណាចទៅឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ និង ៤).ពិភាក្សា និងអនុម័តលើការកែសម្រួលសៀវភៅណែនាំស្តីពីការរៀបចំ និងអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់។

**លទ្ធផលរំពឹងទុកជាអាទិភាពទី២៖ ការរៀបចំ និងការអនុម័តផែនការអនុវត្តរយៈពេលបីឆ្នាំ២០១៨-២០២០ ដំណាក់កាលទី៣ (ផ.អ.៣ទី៣) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

លទ្ធផលរំពឹងទុកនេះបានអនុវត្តសម្រេចតាមផែនការ ដែលរួមមានលទ្ធផលនៃការអនុវត្តដូចខាងក្រោម៖

- ឯកសារទស្សនទាននៃផ.អ.៣ទី៣ត្រូវបានរៀបចំនៅខែមីនា ឆ្នាំ២០១៧។
- សេចក្តីព្រាងបឋមនៃផ.អ.៣ទី៣ ត្រូវបានរៀបចំនៅខែឧសភា ឆ្នាំ២០១៧។
- ក្រុមទីប្រឹក្សាឯករាជ្យត្រូវបានជ្រើសរើស ដើម្បីធ្វើការវាយតម្លៃលើសេចក្តីព្រាងបឋម ផ.អ.៣ទី៣ នាខែមិថុនា ឆ្នាំ២០១៧។

- ក្រុមទីប្រឹក្សាឯករាជ្យបានផ្តល់នូវរបាយការណ៍ចុងក្រោយស្តីពីការវាយតម្លៃរបស់ខ្លួន នៅដើមខែកញ្ញា ឆ្នាំ២០១៧។
- លេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំបញ្ចប់សេចក្តីព្រាងទីមួយនៃផ.អ.៣ទី៣ នៅចុងខែកញ្ញា ឆ្នាំ២០១៧។
- សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាង ផ.អ.៣ទី៣ ជាមួយតំណាងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ នាថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៧។
- ការពិគ្រោះយោបល់លើសេចក្តីព្រាង ផ.អ.៣ទី៣ ជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧។
- ការពិភាក្សា និងអនុម័តរបស់ គ.ជ.អ.ប លើសេចក្តីព្រាង ផ.អ.៣ទី៣ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧។

**លទ្ធផលរំពឹងទុកជាអាទិភាពទី៣៖ ការរៀបចំ និងការអនុវត្តយុទ្ធសាស្ត្រ ដើម្បីលើកកម្ពស់និរន្តរភាពនៃកិច្ចដំណើរការរបស់លេខាធិការដ្ឋាន គ.ជ.អ.ប**

លទ្ធផលរំពឹងទុកនេះបានអនុវត្តសម្រេចតាមផែនការ ដែលរួមមានលទ្ធផលនៃការអនុវត្តដូចខាងក្រោម៖

- លេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំផែនការកាត់បន្ថយការចំណាយផ្នែកប្រតិបត្តិការ និងជំនួយបច្ចេកទេសសម្រាប់ ផ.អ.៣ទី៣ ព្រមទាំងយុទ្ធសាស្ត្រស្តីពីនិរន្តរភាពផ្នែកហិរញ្ញវត្ថុនៃកម្មវិធីរបស់ គ.ជ.អ.ប ដែលយុទ្ធសាស្ត្រនេះបានរៀបចំជាឧបសម្ព័ន្ធនៃ ផ.អ.៣ទី៣។
- លេខាធិការដ្ឋាន គ.ជ.អ.ប បានពិនិត្យ និងកែសម្រួលសៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុរបស់ គ.ជ.អ.ប និងបានរៀបចំជាសេចក្តីព្រាងចុងក្រោយដែលគ្រោងនឹងរៀបចំឱ្យមានការពិភាក្សា និងអនុម័តនៅមុនដំណាច់ឆ្នាំ២០១៧នេះ។

**លទ្ធផលរំពឹងទុកជាអាទិភាពទី៤៖ ការអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង និងផ្សព្វផ្សាយព័ត៌មានសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

ទោះបីជាលទ្ធផលរំពឹងទុកនេះមានភាពយឺតយ៉ាវក្នុងការអនុវត្តប្រៀបធៀបនឹងផែនការដែលគ្រោងទុក ក៏ប៉ុន្តែក៏រួមមានសកម្មភាពមួយចំនួនដែលសម្រេចបានដូចខាងក្រោម៖

- បានបោះពុម្ព និងផ្សព្វផ្សាយនូវសៀវភៅស្តីពីយុទ្ធសាស្ត្រនៃការប្រាស្រ័យទាក់ទង និងផ្សព្វផ្សាយព័ត៌មាន។
- បាននឹងកំពុងរៀបចំផលិតនូវបណ្តុំព័ត៌មាន (រូបថត និងក្រាហ្វិក) ដែលមានគុណភាពខ្ពស់ ដែលរួមមានសំណុំរូបភាពចំនួន១០០សន្លឹក ក្រាហ្វិកចំនួន៣ប្រភេទ យុទ្ធសាស្ត្រក្នុងការប្រើប្រាស់បណ្តាញសង្គម វីដេអូឯកសារចំនួន២ វីដេអូបទសម្ភាសន៍ចំនួន២ និងវីដេអូសាច់រឿងអប់រំខ្លីៗចំនួន២ កម្មវិធីផ្សាយបន្តផ្ទាល់របស់វិទ្យុជាមួយវាគ្មិនចំនួន៤ សាច់រឿងអប់រំខ្លីៗរបស់វិទ្យុចំនួន២ និងបទយកការណ៍ចំនួន២ និងអត្ថបទព័ត៌មានចំនួន៤សម្រាប់ផ្សាយនៅក្នុងកាសែត ដែលបណ្តុំព័ត៌មានទាំងនេះគ្រោងនឹងអនុវត្តនៅត្រីមាសទី៤។

- បានរៀបចំផលិត និងផ្សព្វផ្សាយខិត្តប័ណ្ណចំនួន២ គឺខិត្តប័ណ្ណស្តីពីផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧ និងខិត្តប័ណ្ណស្តីពី ផ.អ.៣ទី២។
- រៀបចំ និងផលិតឧបករណ៍ផ្សព្វផ្សាយសំខាន់ៗរួមមាន ប័ណ្ណព័ត៌មានខ្លីៗ ពាក្យស្លោកខ្លីៗ ប្រតិទិន គំរូបទបង្ហាញ និងកម្រងសំណួរ-ចម្លើយ។
- បានរៀបចំអត្ថបទព័ត៌មាន និងរូបថតផ្សព្វផ្សាយជាទៀងទាត់នូវព្រឹត្តិការណ៍នានា ពាក់ព័ន្ធនឹងកំណែទម្រង់នៅក្នុងគេហទំព័រ គ.ជ.អ.ប និងបានធ្វើបច្ចុប្បន្នភាពគេហទំព័រ ដើម្បីបង្កើនការទាក់ទាញចំណាប់អារម្មណ៍របស់អ្នកអាន។
- បាននឹងកំពុងបន្តរៀបចំផលិត និងផ្សព្វផ្សាយសាច់រឿងអប់រំខ្លីៗតាមទូរទស្សន៍មួយចំនួនស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។
- សាធារណៈជនចំនួន២០.៤៧៨នាក់ បានតាមដានបណ្តាញព័ត៌មានសង្គមរបស់លេខាធិការដ្ឋាន គ.ជ.អ.ប និងមានប្រជាពលរដ្ឋចំនួន២០.២៨២នាក់ទៀតបានចុចលើពាក្យថា "ចូលចិត្តទំព័រហ្វេសប៊ុកនេះ"។
- បានគាំទ្រដល់រដ្ឋបាលខេត្តកំពត ខេត្តបន្ទាយមានជ័យ និងខេត្តក្រចេះ ក្នុងការផលិត និងផ្សព្វផ្សាយពីការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។
- បណ្ណាល័យ គ.ជ.អ.ប បាននឹងកំពុងបញ្ចូលឯកសារទៅក្នុងប្រព័ន្ធផ្ទុកទិន្នន័យថ្មី ដើម្បីដាក់ឱ្យដំណើរការជាបណ្ណាល័យស្វ័យប្រវត្តិ។
- មន្ត្រីជាន់ខ្ពស់របស់លេខាធិការដ្ឋាន គ.ជ.អ.ប បានចូលរួមក្នុងកម្មវិធីកិច្ចពិភាក្សាតាមវិទ្យុទូរទស្សន៍សំខាន់ៗអំពីប្រធានបទសំខាន់នៃកំណែទម្រង់។
- ដោយឡែក យុទ្ធនាការផ្សព្វផ្សាយស្តីពីការផ្ទេរមុខងារវិស័យអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុកដែលគ្រោងអនុវត្តក្នុងត្រីមាសទី៣ពុំទាន់បានអនុវត្តនៅឡើយ ដោយសារការផ្ទេរមុខងារនេះនៅពុំទាន់មានការឯកភាពស្រុះស្រួលគ្នាពីបែបផែននៃការផ្ទេរតាមស្មារតីនៃអនុក្រឹត្យលេខ១៩១អនក្រ.បក នៅឡើយ។

## ខ. សមិទ្ធផលទី២: គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ

សមិទ្ធផលនេះ រួមមានលទ្ធផលរំពឹងទុកជាអាទិភាពចំនួន៣ ដែលក្នុងនោះលទ្ធផលរំពឹងទុកជាអាទិភាពចំនួន៣បានសម្រេចតាមផែនការដែលបានគ្រោងទុក។ វឌ្ឍនភាពនៃលទ្ធផលរំពឹងទុកនីមួយៗមានរៀបរាប់ដូចខាងក្រោម៖

### លទ្ធផលរំពឹងទុកជាអាទិភាពទី១៖ ការអនុវត្តផែនការអនុវត្តការងារគណនេយ្យភាពសង្គមក្នុងស្រុកគោលដៅចំនួន៩៨

លទ្ធផលរំពឹងទុកនេះបានអនុវត្តសម្រេចតាមផែនការ ដែលរួមមានលទ្ធផលនៃការអនុវត្តដូចខាងក្រោម៖

- បានពិនិត្យឡើងវិញ និងឯកភាពលើអនុស្សារណៈយោគយល់គ្នារវាងលេខាធិការដ្ឋាន គ.ជ.អ.ប ជាមួយអង្គការសង្គមស៊ីវិលក្នុងការអនុវត្តការងារគណនេយ្យភាពសង្គមរួមគ្នា នៅក្នុងស្រុកគោលដៅចំនួន៩៨ ដែលមានឃុំគោលដៅចំនួន៧៥៨ សាលាបឋមសិក្សាគោលដៅចំនួន១.៤០០ និងមណ្ឌលសុខភាពគោលដៅចំនួន៥៧០។

- អង្គភាពផ្តល់សេវាទាំង៣ សរុបចំនួន៥.៥៤០អង្គភាពក្នុងស្រុកគោលដៅស្ទើរទាំងអស់បានបញ្ចូលទិន្នន័យស្តីពីកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ និងបានបិទផ្សព្វផ្សាយផ្ទាំងព័ត៌មានទាំងនោះដល់ប្រជាពលរដ្ឋក្នុងតំបន់គោលដៅនីមួយៗ។
- ប្រជាពលរដ្ឋប្រមាណ១៤៦.៥៣៩នាក់ បានចូលរួមនៅក្នុងកិច្ចប្រជុំផ្សព្វផ្សាយកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ។
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយចំនួន១៨លើកដល់ថ្នាក់ដឹកនាំខេត្ត ស្រុក និងស្ថាប័នពាក់ព័ន្ធនានា ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមដែលមានអ្នកចូលរួមប្រមាណ៩៥៣នាក់ (ស្រី១៩៧នាក់)។
- គ្រូបង្គោលថ្នាក់ខេត្តដែលបានបណ្តុះបណ្តាលពីឆ្នាំកន្លងមក បានបន្តបណ្តុះបណ្តាលដល់គ្រូបង្គោលថ្នាក់ស្រុកគោលដៅចំនួន៦២៤នាក់ (ស្រី១៤៥នាក់) ហើយគ្រូបង្គោលថ្នាក់ស្រុកទាំងនេះបានបន្តបណ្តុះបណ្តាលដល់មន្ត្រីនៃអង្គភាពផ្តល់សេវាទាំងបី។
- បានរៀបចំទស្សនកិច្ចសិក្សារបស់គណៈកម្មាធិការគ្រប់គ្រងការអនុវត្តការងារគណនេយ្យភាពសង្គមដើម្បីស្វែងយល់ និងផ្សព្វផ្សាយពីដំណើរការអនុវត្តការងារគណនេយ្យភាពសង្គមចំនួន៣លើក នៅខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ និងខេត្តកោះកុង ដែលមានអ្នកចូលរួមប្រមាណ៧១៦នាក់ (ស្រីចំនួន២៣៥នាក់)។

**លទ្ធផលរំពឹងទុកជាអាទិភាពទី២៖ ការរៀបចំ និងការដាក់ឱ្យអនុវត្តយន្តការសម្រុះសម្រួលដោះស្រាយបណ្តឹងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

លទ្ធផលរំពឹងទុកនេះបានអនុវត្តសម្រេចតាមផែនការ ដែលរួមមានលទ្ធផលនៃការអនុវត្តដូចខាងក្រោម៖

- បានអនុម័ត ផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។
- បានអនុម័ត ផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តសេចក្តីណែនាំ ស្តីពីនីតិវិធីបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។
- បានរៀបចំសេចក្តីព្រាងកែសម្រួលសេចក្តីណែនាំ ស្តីពីនីតិវិធីបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ ក្រុង ស្រុក ខណ្ឌ។
- បាននឹងកំពុងរៀបចំសៀវភៅណែនាំ ស្តីពីនីតិវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងនៅរដ្ឋបាលថ្នាក់ក្រោមជាតិនឹងគ្រោងរៀបចំបញ្ចប់នៅត្រីមាសទី៤។

**លទ្ធផលរំពឹងទុកជាអាទិភាពទី៣៖ ការរៀបចំ និងអនុម័តឯកសារគោលនយោបាយ/ ឯកសារទស្សនទានស្តីពីអធិការកិច្ចរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុកក្នុងការអនុវត្តតាមក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា**

លទ្ធផលរំពឹងទុកនេះបានអនុវត្តសម្រេចតាមផែនការ ដែលរួមមានលទ្ធផលនៃការអនុវត្តដូចខាងក្រោម៖

- បានរៀបចំបញ្ចប់នូវសេចក្តីព្រាងនៃផែនការយុទ្ធសាស្ត្រ ស្តីពីអធិការកិច្ចទៅលើការបំពេញការងាររបស់រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ដែលគ្រោងនឹងដាក់ឱ្យមានការពិភាក្សា និងអនុម័តនៅត្រីមាសទី៤។

### គ. សមិទ្ធផលទី៣÷ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

សមិទ្ធផលនេះ រួមមានលទ្ធផលរំពឹងទុកជាអាទិភាពចំនួន៥ ដែលលទ្ធផលរំពឹងទុកជាអាទិភាពទាំង៥នេះបានអនុវត្តសម្រេចតាមផែនការដែលបានគ្រោងទុក។ វឌ្ឍនភាពនៃលទ្ធផលរំពឹងទុកនីមួយៗមានរៀបរាប់ដូចខាងក្រោម៖

**លទ្ធផលរំពឹងទុកជាអាទិភាពទី១៖ ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវសេចក្ដីណែនាំ ស្ដីពីបែបបទ និងនីតិវិធីសម្រាប់ការជ្រើសរើស ការតែងតាំង ការដំឡើងថ្នាក់ និងការវាយតម្លៃគុណផលបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

លទ្ធផលរំពឹងទុកនេះបានអនុវត្តសម្រេចតាមផែនការ ដែលរួមមានលទ្ធផលនៃការអនុវត្តដូចខាងក្រោម៖

- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយថ្នាក់តំបន់ចំនួន៦លើកនូវព្រះរាជក្រឹត្យស្ដីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដល់ថ្នាក់ដឹកនាំរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទូទាំងប្រទេស ដែលមានអ្នកចូលរួមចំនួនប្រមាណ២.០០០នាក់។
- បាននឹងកំពុងរៀបចំកែសម្រួលសេចក្ដីព្រាងសេចក្ដីណែនាំស្ដីពីបែបបទ និងនីតិវិធីសម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដែលគ្រោងនឹងស្នើសុំការអនុម័ត និងដាក់ឱ្យអនុវត្តនៅត្រីមាសទី៤។

**លទ្ធផលរំពឹងទុកជាអាទិភាពទី២៖ ការលើកកម្ពស់ការបញ្ជ្រាបយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

លទ្ធផលរំពឹងទុកនេះបានអនុវត្តសម្រេចតាមផែនការ ដែលរួមមានលទ្ធផលនៃការអនុវត្តដូចខាងក្រោម៖

- បានអនុម័តផែនការយុទ្ធសាស្ត្រ ស្ដីពីការបង្កើនចំនួនស្ត្រីក្នុងមុខដំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។
- បានបញ្ចប់ឯកសារបណ្ដុះបណ្ដាលស្ដីពីការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមក្នុងភាពជាអ្នកដឹកនាំនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលគ្រោងនឹងរៀបចំវគ្គបណ្ដុះបណ្ដាលនៅគ្រប់រាជធានី ខេត្តនៅត្រីមាសទី៤។
- បានរៀបចំបញ្ចប់នូវរបាយការណ៍សវនកម្មយេនឌ័រដែលបានអនុវត្តនៅចុងឆ្នាំ២០១៦ (សវនកម្មនេះតែងរៀបចំឡើងជារៀងរាល់៣ឆ្នាំម្ដង)។

**លទ្ធផលរំពឹងទុកជាអាទិភាពទី៣៖ ការលើកកម្ពស់សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយប្រើប្រាស់ស្ថាប័នរដ្ឋាភិបាលដែលមានស្រាប់ និងកិច្ចសហការរវាងស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា**

លទ្ធផលរំពឹងទុកនេះបានអនុវត្តសម្រេចតាមផែនការ ដែលរួមមានលទ្ធផលនៃការអនុវត្តដូចខាងក្រោម៖

- ក្រសួងមហាផ្ទៃបានរៀបចំវគ្គបណ្ដុះបណ្ដាលដែលអនុវត្តដោយផ្ទាល់ ដោយអង្គភាពពាក់ព័ន្ធនានារបស់ក្រសួងមហាផ្ទៃ និងដោយមានកិច្ចសហការជាមួយនឹងអង្គការនានាផង មានសរុបចំនួន៩២វគ្គស្ដីពីប្រធានបទសំខាន់ៗដូចជា ១).ការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ចរដ្ឋបាលមូលដ្ឋាន ២).

ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ៣).ការដាក់បញ្ចូលបញ្ហាអប់រំស្ត្រីមានផ្ទៃពោះនៅវ័យក្មេងទៅក្នុងផែនការ អភិវឌ្ឍន៍និងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ៤).ការងារអត្រានុកូលដ្ឋាន និងរបៀបបំពេញស្ថិតិកំណើត អាពាហ៍ពិពាហ៍ និងមរណភាព ៥).ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ ដែលមានអ្នកចូលរួមជាមន្ត្រីរដ្ឋបាលខេត្ត មន្ត្រីនាយកដ្ឋានកិច្ចការក្រុង ស្រុក ឃុំ សង្កាត់ អភិបាលក្រុង ស្រុក មេឃុំ ចៅសង្កាត់ មេភូមិ មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ និងទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាព សរុបចំនួន៥.៧៤៥នាក់ (ស្រី១.០៤២នាក់)។

- ក្រៅពីនោះ រួមមានវគ្គបណ្តុះបណ្តាលជាច្រើនដែលបានរៀបចំដោយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដែលលទ្ធផលនៃវគ្គបណ្តុះបណ្តាលទាំងនោះមានរៀបរាប់នៅក្នុងលទ្ធផលរំពឹងទុកផ្សេងៗទៀត។

**លទ្ធផលរំពឹងទុកជាអាទិភាពទី៤៖ ការលើកកម្ពស់សមត្ថភាពសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក្នុងកិច្ចដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

លទ្ធផលរំពឹងទុកនេះបានអនុវត្តសម្រេចតាមផែនការ ដែលរួមមានលទ្ធផលនៃការអនុវត្តដូចខាងក្រោម៖

- បានផ្តល់វគ្គបណ្តុះបណ្តាលដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់ដឹកនាំរបស់សមាគមក្រុមប្រឹក្សាចំនួន៣វគ្គ ស្តីពីការវិភាគបញ្ហា ការចូលរួមរបស់ប្រជាពលរដ្ឋ និងវឌ្ឍនភាពអំពីវិមជ្ឈការ និងវិសហមជ្ឈការដែលមានអ្នកចូលរួមជាសមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់ដឹកនាំ និងបុគ្គលិកសមាគមសរុបចំនួន២១៦នាក់ (ស្រី២៧នាក់)។
- សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិបានបញ្ចប់របាយការណ៍ស្តីពីការសិក្សាប៉ាន់ស្មាននូវតម្រូវការនៃការអភិវឌ្ឍសមត្ថភាពរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។
- សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំបញ្ចប់មេរៀនចំនួន៤ សម្រាប់បណ្តុះបណ្តាលសមត្ថភាពដល់សមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។
- សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ បានរៀបចំជាសេចក្តីព្រាងបឋមនូវផែនការយុទ្ធសាស្ត្រស្តីពីការស្វែងរកការគាំទ្រយេនឌ័ររបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។

**លទ្ធផលរំពឹងទុកជាអាទិភាពទី៥៖ ការរៀបចំ និងការអនុម័តផែនការអនុវត្តន៍សម្រាប់ការបង្កើត និងការគ្រប់គ្រងសាលាជាតិរដ្ឋបាលមូលដ្ឋាន**

លទ្ធផលរំពឹងទុកនេះបានអនុវត្តសម្រេចតាមផែនការ ដែលរួមមានលទ្ធផលនៃការអនុវត្តដូចខាងក្រោម៖

- បានរៀបចំបង្កើតក្រុមប្រឹក្សាភិបាលរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន។
- បានរៀបចំសេចក្តីព្រាងផែនការសកម្មភាពសម្រាប់ដាក់ឱ្យដំណើរការសាលាជាតិរដ្ឋបាលមូលដ្ឋាន។
- បានរៀបចំផែនការកម្មវិធីសិក្សាសាកល្បងរបស់សាលាជាតិរដ្ឋបាលមូលដ្ឋានសម្រាប់ឆ្នាំ២០១៨។

## ឃ.សមិទ្ធផលទី៤៖ ការផ្តល់សេវា និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

សមិទ្ធផលនេះ រួមមានលទ្ធផលរំពឹងទុកជាអាទិភាពចំនួន២ ដែលក្នុងនោះលទ្ធផលរំពឹងទុកជាអាទិភាពចំនួន១ បានអនុវត្តសម្រេចតាមផែនការដែលបានគ្រោងទុក និងលទ្ធផលរំពឹងទុកជាអាទិភាពចំនួន១មានភាពយឺតយ៉ាវក្នុងការអនុវត្តប្រៀបធៀបនឹងផែនការដែលគ្រោង ។ វឌ្ឍនភាពនៃលទ្ធផលរំពឹងទុកនីមួយៗមានរៀបរាប់ដូចខាងក្រោម៖

**លទ្ធផលរំពឹងទុកជាអាទិភាពទី១៖ ការផ្ទេរ និងអនុវត្តការប្រគល់មុខងារពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធដោយរដ្ឋបាលក្រុង ស្រុក ទាំងអស់ក្នុងខេត្តចំនួន១យ៉ាងតិច**

ទោះបីជាលទ្ធផលរំពឹងទុកនេះមានភាពយឺតយ៉ាវក្នុងការអនុវត្តប្រៀបធៀបនឹងផែនការដែលគ្រោងទុក ក៏ប៉ុន្តែក៏រួមមានសកម្មភាពមួយចំនួនដែលសម្រេចបានដូចខាងក្រោម៖

- បានបញ្ចប់សេចក្តីព្រាងនៃប្រកាស ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ក៏ប៉ុន្តែនៅមានភាពចាំបាច់ក្នុងការបន្តសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធនានា។
- បានបញ្ចប់សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍។
- បានរៀបចំដំណើរទស្សនកិច្ចរួមគ្នារវាងថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា លេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ ដើម្បីពិភាក្សាជាមួយថ្នាក់ដឹកនាំរដ្ឋបាលខេត្ត ក្រុង ស្រុក និងមន្ទីរអប់រំ យុវជន និងកីឡានៅខេត្តបាត់ដំបង។
- បានបញ្ចប់សេចក្តីព្រាងរបាយការណ៍ប្រមូលទិន្នន័យដើមគ្រានៃការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធនៅខេត្តបាត់ដំបង។
- ដោយឡែក ការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិករដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ស្តីពីមុខងារការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធនៅពុំទាន់បានអនុវត្តនៅឡើយ។
- ជាមួយគ្នានេះដែរ ធនធានថវិកា ធនធានមនុស្ស និងទ្រព្យសម្បត្តិពាក់ព័ន្ធនឹងការប្រគល់មុខងារនេះក៏នៅពុំទាន់អនុវត្តនៅឡើយដែរ។

**លទ្ធផលរំពឹងទុកជាអាទិភាពទី២៖ ការបង្កើត និងកិច្ចដំណើរការនៃការិយាល័យច្រកចេញចូលតែមួយ និងយន្តការច្រកចេញចូលតែមួយនៅថ្នាក់ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌចំនួន៥២**

លទ្ធផលរំពឹងទុកនេះបានអនុវត្តសម្រេចតាមផែនការ ដែលរួមមានលទ្ធផលនៃការអនុវត្តដូចខាងក្រោម៖

- បានដាក់ចេញអនុក្រឹត្យលេខ១៨ អនក្រ.បក ស្តីពីការបង្កើតយន្តការរបស់ការិយាល័យច្រកចេញចូលតែមួយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅថ្ងៃទី៨ ខែកុម្ភៈឆ្នាំ ២០១៧។
- បានបង្កើតការិយាល័យច្រកចេញចូលតែមួយនៅថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំនួន៤៦ នៃរាជធានីខេត្តទាំង២៥ ដែលនៅក្នុងនោះមាននៅរដ្ឋបាលក្រុងចំនួន២៦ រដ្ឋបាលស្រុកចំនួន៨ និងរដ្ឋបាលខណ្ឌចំនួន១២ បាននឹងកំពុងផ្តល់សេវារដ្ឋបាលចំនួន២៣៤ប្រភេទសេវាខុសៗគ្នា និងរួមមានអ្នកមកទទួលសេវាចំនួន៤៧៥.៨៣២នាក់ (ស្រី១២៤.៧៣៥នាក់)។
- ការិយាល័យច្រកចេញចូលតែមួយចំនួន៦ទៀតត្រូវបានសាងសង់រួច ហើយគ្រោងនឹងដាក់ឱ្យដំណើរការនៅត្រីមាសទី៤ ឆ្នាំ២០១៧។

- រាជធានី ខេត្តទាំងអស់បានគ្រោងថវិកាសម្រាប់ឆ្នាំ២០១៨ក្នុងការរៀបចំអង្គភាពច្រកចេញចូលតែមួយរបស់រាជធានី ខេត្តនីមួយៗ និងបានគ្រោងថវិកាក្នុងការជួយគាំទ្រដល់ការកសាងការិយាល័យច្រកចេញចូលតែមួយរបស់ស្រុកចំនួន២៣បន្ថែមទៀត។

### ខ. សមិទ្ធផលទី៥÷ វិមជ្ឈការហិរញ្ញវត្ថុ

សមិទ្ធផលនេះ រួមមានលទ្ធផលរំពឹងទុកជាអាទិភាពចំនួន៨ ដែលក្នុងនោះរួមមានលទ្ធផលរំពឹងទុកជាអាទិភាពចំនួន៧បានអនុវត្តសម្រេចតាមផែនការដែលបានគ្រោងទុក លទ្ធផលរំពឹងទុកជាអាទិភាពចំនួន១មានភាពយឺតយ៉ាវក្នុងការអនុវត្តប្រៀបធៀបនឹងផែនការដែលបានគ្រោងទុក។ វឌ្ឍនភាពនៃលទ្ធផលរំពឹងទុកនីមួយៗមានរៀបរាប់ដូចខាងក្រោម៖

**លទ្ធផលរំពឹងទុកជាអាទិភាពទី១៖ ការបង្កើនមូលនិធិក្រុង ស្រុក ផ្នែកអភិវឌ្ឍន៍ ដើម្បីជួយក្រុង ស្រុក មានធនធានសមស្របសម្រាប់អនុវត្តមុខងារជាអាណត្តិទូទៅរបស់ខ្លួន**

លទ្ធផលរំពឹងទុកនេះបានអនុវត្តសម្រេចតាមផែនការ ដែលរួមមានលទ្ធផលនៃការអនុវត្តដូចខាងក្រោម៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាននឹងកំពុងរៀបចំវិភាជថវិកាបន្ថែមចំនួន២លានដុល្លារដែលបានសន្យាផ្តល់ហិរញ្ញប្បទានដោយសហភាពអឺរ៉ុបទៅឱ្យក្រុង ស្រុកនីមួយៗក្នុងការប្រើប្រាស់សម្រាប់ការអភិវឌ្ឍមូលដ្ឋាន។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានឯកភាពក្នុងការបង្កើនធនធានផ្នែកអភិវឌ្ឍន៍នៃមូលនិធិក្រុង ស្រុកឱ្យបានចំនួន០,៥%នៃចំណូលចរន្តថវិកាជាតិចាប់ពីឆ្នាំ២០១៩ តទៅ។

**លទ្ធផលរំពឹងទុកជាអាទិភាពទី២៖ ការពិនិត្យមើលឡើងវិញ និងការរៀបចំរបាយការណ៍រួមគ្នា ស្តីពីលក្ខខណ្ឌសម្រាប់ការចំណាយមូលនិធិក្រុង ស្រុកផ្នែកអភិវឌ្ឍន៍**

លទ្ធផលរំពឹងទុកនេះបានអនុវត្តសម្រេចតាមផែនការ ដែលរួមមានលទ្ធផលនៃការអនុវត្តដូចខាងក្រោម៖

- បានរៀបចំការសិក្សារួមគ្នារវាងលេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ទៅលើស្ថានភាពនៃការអនុវត្តមូលនិធិក្រុង ស្រុក នៅរដ្ឋបាលក្រុង ស្រុកចំនួន១៨ និងបានរៀបចំជាសេចក្តីព្រាងបឋមនៃរបាយការណ៍ ស្តីពីការពិនិត្យមើលឡើងវិញលើការប្រើប្រាស់មូលនិធិក្រុង ស្រុក។ របាយការណ៍នេះគ្រោងនឹងរៀបចំបញ្ចប់ និងដាក់ជូនថ្នាក់ដឹកនាំរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធពិនិត្យ និងសម្រេចនៅត្រីមាសទី៤។

**លទ្ធផលរំពឹងទុកជាអាទិភាពទី៣៖ ការដាក់ឱ្យអនុវត្តនូវយន្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ**

លទ្ធផលរំពឹងទុកនេះបានអនុវត្តសម្រេចតាមផែនការ ដែលរួមមានលទ្ធផលនៃការអនុវត្តដូចខាងក្រោម៖

- បានដាក់ចេញនូវអនុក្រឹត្យលេខ០៦ អនក្រ.បក ស្តីពីការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ កាលពីថ្ងៃទី៥ ខែមករា ឆ្នាំ២០១៧។

- លេខាធិការដ្ឋានគ.ជ.អ.ប និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបាននឹងកំពុងសហការជាមួយក្រសួង ស្ថាប័ននានាដែលបានសម្រេចចិត្តក្នុងការផ្ទេរមុខងារដើម្បីកំណត់អំពីធនធានដែលត្រូវផ្ទេរដោយមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

**លទ្ធផលរំពឹងទុកជាអាទិភាពទី៤៖ ការបន្តការរៀបចំ និងការដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋាននានា ស្តីពីប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមបញ្ចូលទាំងការរៀបចំ សេចក្តីព្រាងអនុក្រឹត្យ ស្តីពីចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

លទ្ធផលរំពឹងទុកនេះបានអនុវត្តសម្រេចតាមផែនការ ដែលរួមមានលទ្ធផលនៃការអនុវត្តដូចខាងក្រោម៖

- បានរៀបចំបញ្ចប់នូវឯកសារគោលនយោបាយស្តីពីប្រភពចំណូលផ្ទាល់។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញប្រកាសលេខ១៥៨៤ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបែងចែងពន្ធលើអចលនទ្រព្យជូនរដ្ឋបាលខណ្ឌ និងសង្កាត់។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាននឹងកំពុងសិក្សា វិភាគ និងប្រឹក្សាយោបល់ជាមួយអ្នកពាក់ព័ន្ធនានាដើម្បីកំណត់អំពីប្រភពចំណូលផ្ទាល់របស់រដ្ឋបាលក្រុង ស្រុក តាមរយៈការបែងចែកចំណូលពន្ធ និងមិនមែនសារពើពន្ធពីរាជធានី ខេត្ត។

**លទ្ធផលរំពឹងទុកជាអាទិភាពទី៥៖ ការរៀបចំបញ្ចប់ និងការអនុម័តនូវលិខិតបទដ្ឋាន និងសេចក្តីណែនាំនានា ស្តីពីការអនុវត្តគម្រោងគាំទ្រ ដោយមូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

លទ្ធផលរំពឹងទុកនេះបានអនុវត្តសម្រេចតាមផែនការ ដែលរួមមានលទ្ធផលនៃការអនុវត្តដូចខាងក្រោម៖

- បានរៀបចំ និងអនុម័តគោលការណ៍ណែនាំ ស្តីពីការវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំសម្រាប់រដ្ឋបាលស្រុក។

**លទ្ធផលរំពឹងទុកជាអាទិភាពទី៦៖ ការរៀបចំ និងការអនុវត្តគម្រោងគាំទ្រដោយមូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព**

ទោះបីជាលទ្ធផលរំពឹងទុកនេះមានភាពយឺតយ៉ាវក្នុងការអនុវត្តប្រៀបធៀបនឹងផែនការដែលគ្រោងទុក ក៏ប៉ុន្តែក៏រួមមានសកម្មភាពមួយចំនួនដែលសម្រេចបានដូចខាងក្រោម៖

- បានជ្រើសរើសខេត្តគោលដៅចំនួន៩ និងស្រុកគោលដៅចំនួន៦២។
- ស្រុកគោលដៅចំនួន៥១ បានដាក់ពាក្យសម្រាប់វាយតម្លៃលើសមិទ្ធកម្មប្រចាំឆ្នាំមកក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (ក.វ.ក)។
- ក្រុមការងាររបស់ ក.វ.ក បានចុះទៅវាយតម្លៃដល់ស្រុកគោលដៅដែលបានដាក់ពាក្យទាំងអស់។ ផ្អែកតាមលទ្ធផលនៃការចុះទៅវាយតម្លៃ រួមមានស្រុកចំនួន១៩ ត្រូវបានសម្រេចថាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការរៀបចំសំណើគម្រោងរបស់ខ្លួនមក ក.វ.ក ដែលគ្រោងថវិកាចំនួន១,២៥លានដុល្លារនៃមូលនិធិនេះសម្រាប់ឆ្នាំ២០១៧។
- ទោះបីជាយ៉ាងនេះក៏ដោយ ក៏ការផ្ទេរធនធានពីមូលនិធិនេះសម្រាប់គាំទ្រគម្រោងក្រុង ស្រុកមិនអាចអនុវត្តទាន់នៅមុនដំណាច់ឆ្នាំ២០១៧នេះឡើយ។

**លទ្ធផលរំពឹងទុកជាអាទិភាពទី៧៖ ការលើកកម្ពស់ប្រសិទ្ធភាព និងតម្លាភាពនៃការអនុវត្តនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

លទ្ធផលរំពឹងទុកនេះបានអនុវត្តសម្រេចតាមផែនការ ដែលរួមមានលទ្ធផលនៃការអនុវត្តដូចខាងក្រោម៖

- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបណ្តុះបណ្តាលអំពីវិធាន និងបទប្បញ្ញត្តិ ស្តីពីលទ្ធកម្មសាធារណៈដល់ប្រធានគណៈកម្មាធិការ និងប្រធានអង្គភាពលទ្ធកម្មក្រុងស្រុករបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានអ្នកចូលរួមសរុបចំនួន ៤៤៥នាក់ (ស្រី១៣២នាក់)។
- អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបណ្តុះបណ្តាលគោលការណ៍ណែនាំអំពីការវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលក្រុងស្រុក ឆ្នាំ២០១៨ ដល់ថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុក ដែលមានអ្នកចូលរួមសរុប១.២៣៣នាក់ (ស្រី២០៥នាក់)។
- អគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបណ្តុះបណ្តាលអំពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុដល់ឃុំ សង្កាត់ទើបបង្កើតថ្មីចំនួន១៣ ដែលមានអ្នកចូលរួមជាស្មៀនឃុំ និងជំនួយការឃុំសង្កាត់ សរុបចំនួន២៨នាក់ (ស្រី៦នាក់)។
- ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការក្រសួងរួមមាន៖ អគ្គនាយកដ្ឋានហិរញ្ញវត្ថុ រដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ បានចុះគាំទ្រ និងត្រួតពិនិត្យការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំនួន៥ខេត្ត (ពោធិ៍សាត់ បាត់ដំបង កំពង់ចាម កំពត និងសៀមរាប) ដែលមានបញ្ហាប្រឈម និងសមត្ថភាពមន្ត្រីនៅមានកម្រិត។

**លទ្ធផលរំពឹងទុកជាអាទិភាពទី៨ ៖ ការផ្សព្វផ្សាយ និងការណែនាំសេចក្តីណែនាំបច្ចេកទេសស្តីពីកិច្ចដំណើរ ការកសាងផែនការអភិវឌ្ឍន៍ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមប្រភេទថ្នាក់រដ្ឋបាលនីមួយៗ**

លទ្ធផលរំពឹងទុកនេះបានអនុវត្តសម្រេចតាមផែនការ ដែលរួមមានលទ្ធផលនៃការអនុវត្តដូចខាងក្រោម៖

- បានអនុម័ត និងដាក់ឱ្យប្រើប្រាស់នូវសេចក្តីណែនាំបច្ចេកទេស ស្តីពីកិច្ចដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានកែសម្រួល។
- បានរៀបចំវគ្គបណ្តុះបណ្តាលដល់គ្រូឧទ្ទេសរាជធានី ខេត្តអំពីសេចក្តីណែនាំបច្ចេកទេសស្តីពីកិច្ចដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានកែសម្រួល ព្រមទាំងវិធីសាស្ត្រនៃការស្រង់ និងការគ្រប់គ្រងទិន្នន័យមូលដ្ឋានចំនួន៧វគ្គដែលមានអ្នកចូលរួមសរុបប្រមាណជិត៦០០នាក់។

## III. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធិផលសម្រេចបាន ក៏នៅមានបញ្ហាប្រឈមមួយចំនួន ដែលបានជួបប្រទះរួមមានដូចខាងក្រោមៈ

- **ការទម្លាក់ថវិកាពីដៃគូអភិវឌ្ឍន៍នៅតែមានភាពយឺតយ៉ាវ។** ជារួម ផ.ស.ថ ប្រចាំឆ្នាំរបស់ គ.ជ.អ.ប បានកំណត់នូវសកម្មភាពចម្បងៗ និងគ្រោងប្រើប្រាស់ថវិកាចាប់តាំងពីដើមឆ្នាំនីមួយៗ អាស្រ័យហេតុនេះតម្រូវឱ្យ គ.ជ.អ.ប ផ្ទេរពីដើមឆ្នាំនូវថវិកាមួយចំនួនជាបឋមទៅឱ្យស្ថាប័នអនុវត្តទាំង៤៦។ យ៉ាងណាមិញថវិកាដែលត្រូវផ្ទេរជាបឋមទៅឱ្យស្ថាប័នអនុវត្តនីមួយៗ ភាគច្រើនបានមកពីការផ្ទេរនូវថវិកាដែលសេសសល់មានចំនួនតិចតួចពីឆ្នាំមុន ដែលចំនួននេះអាចប្រើប្រាស់បានតែសម្រាប់ការចំណាយផ្នែករដ្ឋបាល និងសកម្មភាពសំខាន់ៗមួយចំនួនតិចតួច ក្នុងដំណាក់កាលពី២ទៅ៣ខែដើមឆ្នាំដំបូងតែប៉ុណ្ណោះ។ ស្ថានភាពនេះក៏បានកើតឡើងនៅក្នុងឆ្នាំ២០១៧នេះផងដែរ។ ដោយឡែក ថវិកាដែលបានសន្យាផ្តល់ពីដៃគូអភិវឌ្ឍន៍ (Sida និង SDC) សម្រាប់ឆ្នាំ២០១៧ ត្រូវបានផ្ទេរមកឱ្យលេខាធិការដ្ឋាន គ.ជ.អ.ប នៅខែឧសភា ឆ្នាំ២០១៧ និងពីសហភាពអឺរ៉ុបតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅខែកញ្ញា ឆ្នាំ២០១៧។ ភាពយឺតយ៉ាវនៃការទម្លាក់ថវិកាពីដៃគូអភិវឌ្ឍន៍ បានបង្កឱ្យមានការរាំងស្ទះក្នុងការអនុវត្តនូវសកម្មភាពសំខាន់ៗមួយចំនួនដែលបានគ្រោងអនុវត្តនៅក្នុងត្រីមាសទី១ និងត្រីមាសទី២។

- **កិច្ចដំណើរការផ្ទេរមុខងារនៅមានភាពយឺតយ៉ាវ។** ទោះបីមានក្រសួង ស្ថាប័នមួយចំនួនបានសម្រេចចិត្តផ្ទេរមុខងារសមស្របមួយចំនួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ប៉ុន្តែនៅមានក្រសួង ស្ថាប័នជាច្រើនទៀត ដែលនៅមានភាពស្ទាក់ស្ទើរក្នុងការសម្រេចចិត្តផ្ទេរមុខងារសមស្របក្នុងវិស័យរបស់ខ្លួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយគ្នានោះដែរ មុខងារមួយចំនួនក្នុងចំណោមមុខងារដែលបានផ្ទេរ ក៏នៅពុំទាន់បានអនុវត្តយ៉ាងពេញលេញដោយរដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយ ដោយសារការគាំទ្រផ្នែកបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពពីក្រសួង ស្ថាប័នសាមីនៅមានកម្រិត ហើយក៏មានករណីខ្លះកើតឡើង ដោយសារតែពុំមានការដាក់ចេញនូវសេចក្តីណែនាំបច្ចេកទេសលម្អិតឱ្យបានគ្រប់គ្រាន់ក្នុងការអនុវត្តនូវមុខងារនោះផងដែរ។ ដោយឡែក មុខងារជាជម្រើស ឬមុខងារជាអាណត្តិទូទៅរបស់រដ្ឋបាលមូលដ្ឋានក៏នៅតែជាបញ្ហាប្រឈមនៅឡើយ។ ទោះបីមានការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំបច្ចេកទេស ព្រមទាំងការរៀបចំវគ្គបណ្តុះបណ្តាលជាច្រើនដល់រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងមុខងារជាជម្រើសក៏ដោយ ក៏ប៉ុន្តែមកទល់បច្ចុប្បន្ននេះរួមមានរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួនតិចតួចប៉ុណ្ណោះ ដែលបានអនុវត្តនូវមុខងារជាជម្រើសមួយចំនួនរបស់ខ្លួន។ ផ្អែកតាមការសិក្សាស្រាវជ្រាវ បញ្ហានេះកើតឡើងដោយមូលហេតុពីរជាសំខាន់ ពោលគឺ ទី១.ថវិការបស់រដ្ឋ បាលថ្នាក់ក្រោមជាតិមានចំនួនតិចតួច ដែលពុំអាចប្រើប្រាស់ទៅលើមុខងារជាជម្រើសនានាផ្សេងទៀតក្រៅពីគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងទី២.ការយល់ដឹងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនក្នុងការអនុវត្តនូវមុខងារជាជម្រើស នៅមានភាពពុំទាន់បានច្បាស់លាស់ដែលធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានការរារែកក្នុងការអនុវត្ត ដោយមានការព្រួយបារម្ភខ្លាចប៉ះពាល់ដល់អាណត្តិរបស់ក្រសួងស្ថាប័នជំនាញនានា។

- **ប្រព័ន្ធអធិការកិច្ចទៅលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅពុំទាន់មានប្រសិទ្ធភាព។** ជារួម ការធ្វើអធិការកិច្ចទៅលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិនាពេលបច្ចុប្បន្នកំពុងអនុវត្តតាមប្រព័ន្ធអធិការកិច្ចដែលមានជាធរមានដែលពុំទាន់ត្រូវបានកែលម្អឱ្យសមស្របទៅតាមកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិតម្រូវឱ្យមានប្រព័ន្ធអធិការកិច្ចដ៏ច្បាស់លាស់ និងសមស្របមួយទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

- **ការប្រាស្រ័យទាក់ទង និងផ្សព្វផ្សាយព័ត៌មានអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅមានកម្រិត។** ជារួម កិច្ចដំណើរការកំណែទម្រង់វិមជ្ឈការមានភាពស្មុគស្មាញសាំញ៉ាំដែលទាមទារឱ្យមានការយល់ដឹង និងចូលរួមពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់រួមបញ្ចូលទាំងអ្នកនយោបាយ អ្នកបច្ចេកទេស និងសាធារណជនទូទៅ។ នៅក្នុងការអនុវត្តគោលនយោបាយកំណែទម្រង់នេះក៏តម្រូវឱ្យមានការផ្លាស់ប្តូរនូវឥរិយាបទក្នុងការបំពេញការងាររបស់មន្ត្រីរាជការផងដែរ។ កន្លងមកនេះ សកម្មភាពផ្សព្វផ្សាយនានា ដើម្បីលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីកំណែទម្រង់នៅមានកម្រិតនៅឡើយ។ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិភាគច្រើននៅពុំទាន់បានចូលរួមធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយកំណែទម្រង់នៅក្នុងស្ថាប័នរបស់ខ្លួនឱ្យបានទូលំទូលាយនៅឡើយ។ មធ្យោបាយផ្សព្វផ្សាយដ៏មានប្រសិទ្ធភាពមួយចំនួន ឧទាហរណ៍ដូចជាការប្រើប្រាស់បណ្តាញព័ត៌មានសង្គម ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី មហោស្រពសិល្បៈជាដើមក៏នៅពុំទាន់បានប្រើប្រាស់យ៉ាងទូលំទូលាយនៅឡើយ។

- **ការអនុវត្តមូលនិធិក្រុង ស្រុកនៅពុំទាន់ឆ្លើយតបនឹងតម្រូវការនៃការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។** ជារួម មូលនិធិក្រុង ស្រុកបានចំណាយភាគច្រើនទៅលើបន្ទុកបុគ្គលិក និងចំណាយផ្នែកកិច្ចការរដ្ឋបាលដែលធ្វើឱ្យធនធានសម្រាប់ប្រើប្រាស់ក្នុងការផ្តល់សេវាកម្ម និងការអភិវឌ្ឍមូលដ្ឋានមានចំនួនតិចតួចដែលពុំអាចឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពជាច្រើននៅមូលដ្ឋាន។ ក្រៅពីគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចនានាដែលមានសារសំខាន់ និងជាតម្រូវការដ៏ចាំបាច់របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន រដ្ឋបាលថ្នាក់ក្រោមជាតិក៏ចាំបាច់ក្នុងការដោះស្រាយនូវសេវាសង្គមសំខាន់ៗមួយចំនួន ដែលមានលក្ខណៈអន្តរវិស័យ ហើយពុំមានស្ថាប័នទទួលខុសត្រូវច្បាស់លាស់។ ទោះបីមូលនិធិវិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើតឡើងរួចហើយ ក៏ប៉ុន្តែមូលនិធិនេះនៅពុំទាន់អាចផ្ទេរធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយ។

- **ការចូលរួមរបស់ក្រសួង ស្ថាប័នក្នុងកិច្ចដំណើរការកំណែទម្រង់នៅមានកម្រិតនៅឡើយ។** មកទល់បច្ចុប្បន្ននេះ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រតាមវិស័យនីមួយៗរបស់ក្រសួង ស្ថាប័នភាគច្រើននៅពុំទាន់បានដាក់បញ្ចូលនូវសកម្មភាពនានា និងធនធានសម្រាប់គាំទ្រកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យរបស់ខ្លួននៅឡើយ។

## IV. ស្ថានភាពថវិកា

ផ.ស.ថ ឆ្នាំ២០១៧ បានគ្រោងថវិកាសរុបចំនួនប្រមាណ៤៣៨លានដុល្លារ ដែលក្នុងនោះរួមមានថវិកាដែលត្រូវផ្ទេរពីថវិកាជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិចំនួនប្រមាណ៣៩៧លានដុល្លារ ថវិកាដែលគាំទ្រគម្រោងដាច់ដោយឡែកនានារបស់ដៃគូអភិវឌ្ឍន៍ចំនួនប្រមាណ២៧លានដុល្លារ និងថវិកាកញ្ចប់រួមដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍សម្រាប់គាំទ្រដល់កិច្ចប្រតិបត្តិការ ជំនួយបច្ចេកទេស និងសកម្មភាពនានាមានចំនួនប្រមាណ១១,៦ លានដុល្លារ។ របាយការណ៍នេះ ផ្តោតតែទៅលើស្ថានភាពគ្រប់គ្រងថវិកាកញ្ចប់រួមតែប៉ុណ្ណោះ។ រហូតមកទល់នឹងខែកញ្ញា ឆ្នាំ២០១៧នេះ លេខាធិការដ្ឋាន គ.ជ.អ.ប បានទទួលថវិកាចំនួនប្រមាណ៨,២លានដុល្លារ ដែលក្នុងនោះរួមមាន ថវិកាផ្ទេរពីឆ្នាំ២០១៦ ចំនួនប្រមាណ១,៥លានដុល្លារ និងថវិកាដែលបានផ្ទេរពីដៃគូអភិវឌ្ឍន៍នានាចំនួនប្រមាណ៦,៧លានដុល្លារ។ ដោយឡែកមកទល់ចុងខែកញ្ញានេះដែរ ការចំណាយលើការអនុវត្តកម្មវិធីមានចំនួនសរុបជិត៦លានដុល្លារ ដែលស្មើនឹងចំនួន៥០% នៃផែនការថវិកាកញ្ចប់រួមរបស់ ផ.ស.ថ ឆ្នាំ២០១៧។ ការចំណាយដែលមានចំនួនភាគរយទាបធៀបនឹងចិរវេលានៃផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ គឺបណ្តាលមកពីភាពយឺតយ៉ាវនៃការរៀបចំសេចក្តីសម្រេចរួមរវាងក្រសួង ស្ថាប័នអនុវត្តនីមួយៗជាមួយនឹង គ.ជ.អ.ប ដែលបានប្រើប្រាស់ពេលវេលាប្រមាណពី៣ ទៅ ៤ខែនៅដើមឆ្នាំ ព្រមទាំងភាពយឺតយ៉ាវនៃការផ្ទេរថវិកាពីដៃគូអភិវឌ្ឍន៍មួយចំនួនដូចបានរៀបរាប់នៅក្នុងបញ្ហាប្រឈមខាងលើ។ យ៉ាងណាមិញ រហូតដល់ចុងឆ្នាំ២០១៧ លេខាធិការដ្ឋាន គ.ជ.អ.ប បានព្យាករណ៍អំពីការចំណាយដែលអាចមានចំនួនប្រមាណ៨០% នៃផែនការថវិកាកញ្ចប់រួមប្រចាំឆ្នាំ។

**តារាងទី១៖ ស្ថានភាពនៃការផ្ទេរ និងការចំណាយថវិកាកញ្ចប់រួមតាមប្រភពដៃគូអភិវឌ្ឍន៍ (គិតជាដុល្លារ)**

| ដៃគូអភិវឌ្ឍន៍ | ថវិកាកញ្ចប់រួមគ្រោងសម្រាប់ ផ.ស.ថ ឆ្នាំ២០១៧ | ថវិកាផ្ទេរពីឆ្នាំ ២០១៦ (ក) | ថវិកាដែលបានផ្ទេរពីដៃគូគិតដល់ខែកញ្ញា ២០១៧ (ខ) | សរុប (ក) + (ខ) | ចំណាយគិតត្រឹមខែកញ្ញា | %នៃចំណាយធៀបនឹងគម្រោងថវិកា |
|---|---|---|---|---|---|---|
| សហភាពអឺរ៉ុប | 5,847,174 | | 3,000,000 | 3,000,000 | 3,241,156 | 55% |
| ស៊ុយអែដ | 3,752,732 | 1,068,660 | 2,754,265 | 3,822,925 | 1,298,100 | 35% |
| ស្វីស | 2,084,810 | 463,590 | 1,000,000 | 1,463,590 | 1,297,614 | 62% |
| **សរុបរួម** | **11,684,716** | **1,532,251** | **6,754,265** | **8,286,516** | **5,836,870** | **50%** |

**តារាងទី២៖ ចំណាយធៀបនឹងផែនការថវិកាតាមសមិទ្ធផលរំពឹងទុកនីមួយៗ គិតត្រឹមចុងខែកញ្ញា (គិតជាដុល្លារ)**

| ពិពណ៌នាមុខចំណាយ | ថវិកាកញ្ចប់រួមគ្រោងសម្រាប់ ផ.ស.ថ ឆ្នាំ២០១៧ | ចំណាយគិតត្រឹមខែកញ្ញា | សមតុល្យ | %នៃចំណាយធៀបនឹងគម្រោងថវិកា |
|---|---|---|---|---|
| សមិទ្ធផលរំពឹងទុកទី១ | 1,191,352.00 | 449,544.44 | 741,807.56 | 38% |
| សមិទ្ធផលរំពឹងទុកទី២ | 962,407.00 | 323,330.86 | 639,076.14 | 34% |
| សមិទ្ធផលរំពឹងទុកទី៣ | 1,351,943.00 | 501,347.67 | 850,595.16 | 37% |
| សមិទ្ធផលរំពឹងទុកទី៤ | 893,341.00 | 217,091.48 | 676,249.52 | 24% |
| សមិទ្ធផលរំពឹងទុកទី៥ | 381,965.00 | 146,160.91 | 235,804.09 | 38% |
| បុគ្គលិក និងប្រតិបត្តិការ | 6,903,708.00 | 4,199,393.91 | 2,704,314.09 | 61% |
| សរុបរួម | **11,684,716.00** | **5,836,869.44** | **5,847,846.56** | **50%** |

## V. ទិសដៅសម្រាប់ត្រីមាសទី៤ ឆ្នាំ២០១៧

ទិសដៅសម្រាប់ត្រីមាសទី៤នៃផែនការសកម្មភាព និងថវិកា ឆ្នាំ២០១៧រួមមាន៖

- រៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៨ របស់ គ.ជ.អ.ប។
- រៀបចំកិច្ចប្រជុំ គ.ជ.អ.ប លើកទី១៥ ដើម្បីពិនិត្យ និងអនុម័តផែនការសកម្មភាព និងថវិកាឆ្នាំ២០១៨ របស់គ.ជ.អ.ប និងបញ្ហាផ្សេងៗទៀត។
- រៀបចំបញ្ចប់ និងផ្សព្វផ្សាយនូវបណ្តុំព័ត៌មាន ដើម្បីលើកកម្ពស់ការប្រាស្រ័យទាក់ទង និងផ្សព្វផ្សាយព័ត៌មានរបស់ គ.ជ.អ.ប សំដៅធានាឱ្យមានភាពប្រសើរឡើងនូវការយល់ដឹងអំពីកំណែទម្រង់វិមជ្ឈការ។
- រៀបចំបញ្ចប់ និងអនុម័តនូវផែនការយុទ្ធសាស្ត្រ ស្តីពីការធ្វើអធិការកិច្ចលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- រៀបចំបញ្ចប់ និងអនុម័តនូវសេចក្តីណែនាំអំពីនីតិវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋ។
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមដែលថ្នាក់ដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ត្រូវចូលរួមជាកាតព្វកិច្ច។
- រៀបចំ និងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រសម្រាប់ស្វែងរកការគាំទ្រដល់សមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិជាស្ត្រី។
- រៀបចំ និងអនុម័តផែនការយុទ្ធសាស្ត្រ និងផែនការអនុវត្តរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន។
- បន្តរៀបចំសម្របសម្រួលការផ្ទេរមុខងារពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធដល់រដ្ឋបាលក្រុង ស្រុក។
- បន្តសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានាក្នុងការរៀបចំកិច្ចដំណើរការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។
- បញ្ចប់លិខិតបទដ្ឋាន និងសៀវភៅណែនាំស្តីពីការរៀបចំគម្រោងដែលគាំទ្រដោយមូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- រៀបចំបញ្ចប់នូវរបាយការណ៍ស្តីពីស្ថានភាពនៃការអនុវត្តមូលនិធិក្រុង ស្រុក។
- រៀបចំទស្សនកិច្ចសិក្សារួមគ្នាជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីចុះពិនិត្យមើលការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

របាយការណ៍៩ខែដើមឆ្នាំនៃការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧ របស់ គ.ជ.អ.ប ត្រូវបានពិនិត្យ និងអនុម័តដោយកិច្ចប្រជុំលើកទី១៤ របស់ គ.ជ.អ.ប នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧។